# គោលការណ៍វិសុទ្ធលប្លុំទីង

## គោលនយោបាយ

ធនាគារគ្មានការលើកលែង នៅលើទម្រង់នៃការប្រព្រឹត្តិខុសឆ្គង ឬការរំលោភសិទ្ធអាជីវកម្ម ដែលស្រប ទៅ តាមក្រម សីលធម៌ និងគុណតម្លៃរួម។

ជាផ្នែកមួយនៃគោលការណ៍នេះ រាល់ទម្រង់នៃ ការលួចបន្លំ ការសូកប៉ាន់ ឬអំពើពុករលួយ មិនត្រូវ ទទួលស្គាល់ពី ធនាគារ ដោយមិនគិតពីអត្តសញ្ញាណ មុខតំណែងរបស់បុគ្គលដែលពាក់ព័ន្ធ និងការរំលោភ ណាមួយរបស់បុគ្គលិក ឬដៃគូពាណិជ្ជកម្ម គឺមិនត្រូវបានលើកលែងឡើយ។

រាល់សកម្មភាពក្លែងបន្លំ និងការសូកប៉ាន់ ឬពុករលួយគឺជាបទល្មើសព្រហ្មទណ្ឌ និងជាការរំលោភ យ៉ាងច្បាស់ ទៅលើ ក្រមសីលធម៌ និងគុណតម្លៃរួម (P.R.I.D.E)។ អាក្បកិរិយា ឬសកម្មភាពដែលផ្ទុយពីគោល ការណ៍ និងគុណតម្លៃ របស់ធនាគា ក៏ដូចជា រាល់ការរំលោភបំពានច្បាប់កម្ពុជា និងបទបញ្ជា ណាមួយ គឺត្រូវ បានហាមឃាត់យ៉ាងតឹងរឹង។

រាល់បុគ្គលិកទាំងអស់ គឺត្រូវតែបន្តអនុវត្តស្របទៅតាមបទដ្ឋានខ្ពស់បំផុតនៃសេចក្តីទៀងត្រង់ ឥរិយា បទ ប្រកបដោយ សីលធម៌ វិជ្ជាជីវៈ ស្មោះត្រង់ និងស្មើភាព នៅក្នុងអាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ និងការរៀបចំ ប្រតិបត្តិការ។ ម្យ៉ាងទៀតបុគ្គលិកទាំងអស់គឺត្រូវតែប្តេជ្ញាក្នុងការទប់ស្កាត់ បង្ការ និងរកឲ្យឃើញនូវទម្រង់នៃការ ប្រព្រឹត្តមិនត្រឹមត្រូវ ឬអាក្បកិរិយា គ្មានក្រមសីលធម៌ដោយមិនមានកំណត់ចំពោះការលួចបន្លំ សកម្មភាពការ ប្រឆាំងនឹងការប្រកួតប្រជែង ការលួចទិន្នន័យ ផ្ទាល់ខ្លួន ការបង្ហាញនូវព៌ត៌មាន អតិជនដោយគ្មានការអនុញ្ញាត ការសូកប៉ាន់ និងអំពើពុករលួយដែលពាក់ព័ន្ធនឹងធនាគារ។

## ការការពារអ្នកអនុវត្តគោលការណ៍វិសុទ្ធលប្លុំទីង

ធនាគារទទួលស្គាល់ថា និយោជិកគឺអ្នកនាំមុខចំពោះព័ត៌មានដែលពាក់ព័ន្ធ ហើយជាទូទៅអ្នកដែល រកឃើញនូវកំហុសឆ្គង ឬអំពើមិនត្រឹមត្រូវមុនគេនៅក្នុងធនាគារ។

ការព្រួយបារម្ភមួយចំនួនអាចមិនសមហេតុផល និងអាចត្រូវបានដោះស្រាយដោយការយោគយល់។ ផ្ទុយទៅវិញ ក៏មានការព្រួយបារម្ភដែលអាចសន្និដ្ឋានបានថាជាបញ្ហាតូចតាច ដែលវាអាចឈានដល់បញ្ហា ធ្ងន់ធ្ងរពាក់ព័ន្ធនឹង បទឧក្រិដ្ឋ ហើយ ប្រហែលអាចមានផលប៉ះពាល់ទៅលើកេរ្តិ៍ឈ្មោះធនាគារ និងស្ថានភាព ហិរញ្ញវត្ថុផងដែរ។

ទោះបីយ៉ាងណាក៏ដោយ សម្រាប់ការភ័យខ្លាចសុវត្ថិភាពផ្ទាល់ខ្លួន ការរើសអើង និងសុវត្ថិភាពការងារ និយោជិកមិនហ៊ាន បញ្ចេញការព្រួយបារម្ភពួកគេ ទាក់ទងទៅនឹងការប្រព្រឹត្តខុសច្បាប់ឬ បញ្ហាមិនប្រតិបត្តិតាម ដែលអាច ឬត្រូវបានប្រព្រឹត្តដោយ អ្នកធ្វើការជាមួយ ឬ មន្ត្រីថ្នាក់លើរបស់ពួកគេ។ ការការពារវិសុទ្ធលប្លុំវើរ គឺត្រូវ បានបញ្ជាក់នូវក្រោមច្បាប់ និងបទបញ្ញត្តិប្រទេសកម្ពុជាដូចខាងក្រោម៖

ក.	ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (២០១០) បានចង្អុលបង្ហាញថា រាល់ខ្សែបណ្តាញរាយការណ៍គ្រប់គ្រាន់ និងឯករាជ្យគួរត្រូវបានបង្កើតឡើងដើម្បីអនុវត្ត គោលការណ៍វិស្សលប្លូវឹងយ៉ាងសំងាត់។ ច្បាប់ការពារបុគ្គលត្រូវបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកទាំងអស់ ដែលធ្វើការស្មោះត្រង់ និងផ្តល់ផលប្រយោជន៍រួមដល់ក្រុមហ៊ុន។

ខ.	ប្រការ១៣ នៃច្បាប់ប្រឆាំងអំពើពុករលួយ (២០១០) បានចែងច្បាស់ថា អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវចាត់វិធានការចាំបាច់ដើម្បីរក្សាសុវត្ថិភាពវិស្សលប្លូវើរ។

## មធ្យោបាយវិស្សលប្លូវឹង

ក.	របាយការណ៍ និងពាក្យបណ្តឹងគួរតែបញ្ជូនទៅដោយផ្ទាល់ដល់អ្នកទទួលដែលបានត្រូវតែងតាំងដូចខាងក្រោម៖

អ៊ីម៉ែល៖ kh.whistleblowing@rhbgroup.com

ខ.	ធនាគារអាននឹងចូលរួមជាមួយអ្នកផ្តល់សេវាកម្មខាងក្រៅ ដើម្បីក្លាយជាភាគីដែលត្រូវបានអនុញ្ញាត្ត ជាអ្នកទទួល ដែលបានត្រូវតែងតាំងដោយធនាគារ ដើម្បីទទួលរបាយការណ៍វិស្សលប្លូវឹងក្នុងនាមជាគ្រឹះស្ថានធនាគារ បន្ទាប់ពីការ អនុម័តរបស់ក្រុមប្រឹក្សាភិបាល។

គ.	ការផ្លាស់ប្តូរណាមួយនៅក្នុងបញ្ជីដែលបានអនុញ្ញាត្តរបស់អ្នកទទួលដែលបានត្រូវតែងតាំង នឹងត្រូវបង្ហាញក្នុង គោលនយោបាយ ផ្ទៃក្នុង ការណែនាំ និង/ឬនីតិវិធីដែលពាក់ព័ន្ធ បន្ទាប់ពីការ អនុម័តរបស់ក្រុមប្រឹក្សាភិបាល។